**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..០០៤៦........អបស.អធម/ប្រក

# ប្រកាស

## ស្តីពី

## ស្តង់ដារអប្បបរមា នៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៥ មាត្រា៧ មាត្រា១២ មាត្រា១៧ នៃអនុក្រឹត្យលេខ ២១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ និងមាត្រា៦ថ្មី នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញប្រកាសលេខ ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញប្រកាសលេខ ៤២៨ អបស.អធម/ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តនូវកម្មវិធីសិក្សាជាតិថ្នាក់បរិញ្ញាបត្ររងឆ្មប នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះកំណត់អំពីបែបបទ និងលក្ខខណ្ឌអប្បបរមានៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ក្នុងគោលបំណង ជានាឱ្យបាននូវគុណភាពនៃការធ្វើកម្មសិក្សាដោយផ្តោតលើការអប់រំផ្អែកលើសមត្ថភាពជាមូលដ្ឋាន តាមរយៈការបង្កើតយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ការអនុវត្តកម្មសិក្សាគ្លីនិករបស់និស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប ដែលកំពុងទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ដែលមានអាជ្ញាបណ្ណស្របច្បាប់។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ទាំងសាធារណៈ និងឯកជនដែលមានអាជ្ញាបណ្ណស្របច្បាប់ ក្នុងការបណ្តុះបណ្តាលកម្មសិក្សាគ្លីនិកដល់និស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប ស្របតាមកម្មវិធីសិក្សាជាតិ ដោយសហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាល។

**ប្រការ ៣.-**

បច្ចេកស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

- **គ្រឹះស្ថានបណ្តុះបណ្តាល** សំដៅដល់គ្រឹះស្ថានដែលផ្តល់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ទាំងសាធារណៈ និងឯកជនដែលមានអាជ្ញាបណ្ណស្របច្បាប់ រួមមានជាអាទិ៍៖ សាកលវិទ្យាល័យ វិទ្យាស្ថាន សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ និងសាខាដែលធ្វើការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលគ្រប់ជំនាញ និងគ្រប់កម្រិត។
- **គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក** សំដៅដល់មូលដ្ឋានសុខាភិបាល ដែលទទួលបានការអនុញ្ញាតជាកន្លែងអនុវត្តកម្មសិក្សាគ្លីនិកពីក្រសួងសុខាភិបាល។
- **មូលដ្ឋានសុខាភិបាល** សំដៅដល់ទីកន្លែងបម្រើសេវាសុខាភិបាល ទាំងសាធារណៈ និងឯកជន។
- **ប្រធាន** សំដៅដល់អ្នកគ្រប់គ្រងអង្គភាព រួមមាន អគ្គនាយក សាកលវិទ្យាធិការ និងនាយក។
- **កម្មវិធីសិក្សាជាតិ** សំដៅដល់ឯកសារដែលពិពណ៌នាអំពីមុខវិជ្ជា ឬប្រធានបទជាក់លាក់ដែលរួមបញ្ចូលគ្នាតាមលំដាប់លំដោយបង្កើតបានជាកម្មវិធីបណ្តុះបណ្តាលមួយដែលជាការអប់រំផ្អែកលើសមត្ថភាព។
- **គ្រូកម្មសិក្សាមន្ទីរពេទ្យ (Preceptor)** សំដៅដល់គ្រូបង្រៀនអនុវត្តគ្លីនិក ដែលទទួលបានការបណ្តុះបណ្តាលវគ្គគ្រូកម្មសិក្សាមន្ទីរពេទ្យផ្នែកធ្មប ដែលកំពុងបម្រើការនៅតាមមូលដ្ឋានសុខាភិបាល ដោយសហការបង្រៀនអនុវត្តគ្លីនិកជាមួយគ្រូកម្មសិក្សាសាលា។
- **គ្រូកម្មសិក្សាសាលា (Clinical instructor)** សំដៅដល់គ្រូរបស់សាលា ដែលទទួលបានការបណ្តុះបណ្តាលវគ្គគ្រូកម្មសិក្សាមន្ទីរពេទ្យផ្នែកធ្មប មានតួនាទីដឹកនាំនិស្សិតទៅធ្វើកម្មសិក្សានៅតាមគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ដោយសហការបង្រៀនអនុវត្តគ្លីនិកជាមួយគ្រូកម្មសិក្សាមន្ទីរពេទ្យ។
- **ការអនុវត្តកម្មសិក្សាគ្លីនិក** សំដៅដល់ការអនុវត្តជំនាញគ្លីនិកជាក់ស្តែងជាមួយអ្នកជំងឺនៅតាមគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក។
- **កិច្ចព្រមព្រៀង** សំដៅដល់ការឯកភាពគ្នារវាងទ្វេភាគី ឬច្រើនភាគី ចំពោះលក្ខខណ្ឌ និងការយោគយល់គ្នាជាលម្អិតដែលរួមមានការតម្រូវ និងការទទួលខុសត្រូវរបស់ភាគីនីមួយៗ។
- **អនុបាតរវាងនិស្សិត និងអ្នកជំងឺ និង/ឬស្ត្រីមកទទួលសេវា** សំដៅដល់សមាមាត្ររវាងចំនួននិស្សិត និងចំនួនអ្នកជំងឺ និង/ឬស្ត្រីមកទទួលសេវា។
- **អនុបាតរវាងគ្រូកម្មសិក្សាមន្ទីរពេទ្យ និងនិស្សិត** សំដៅដល់សមាមាត្ររវាងគ្រូកម្មសិក្សាមន្ទីរពេទ្យ និងចំនួននិស្សិត។

## ជំពូកទី ២
## បែបបទ និងលក្ខខណ្ឌ នៃសង្គាជារអប្បបរមា

### ផ្នែកទី ១
### បែបបទក្នុងការទទួលយកនិស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប អនុវត្តកម្មសិក្សាគ្លីនិក

**ប្រការ ៤.-**

គ្រឹះស្ថានបណ្តុះបណ្តាលត្រូវបញ្ជូនផែនការកម្មសិក្សាប្រចាំឆ្នាំជូនគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកនៅរៀងរាល់ខែវិច្ឆិកានៃឆ្នាំនីមួយៗ។

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកត្រូវរៀបចំផែនការ នៃលទ្ធភាពទទួលយកនិស្សិតមកអនុវត្តកម្មសិក្សា ស្របតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងប្រកាសនេះ និងរបាយការណ៍ និស្សិតកំពុងធ្វើកម្មសិក្សាជាក់ស្តែង បញ្ជូនមកអង្គភាពជំនាញ នៃក្រសួងសុខាភិបាលរៀងរាល់ខែធ្នូនៃឆ្នាំនីមួយៗ។

**ប្រការ ៥.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវសហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាល សម្រាប់ការបង្រៀន តាមដាន និងវាយតម្លៃការអនុវត្តគ្លីនិករបស់និស្សិតឱ្យបានត្រឹមត្រូវ និងស្របតាមតម្រូវការរបស់កម្មវិធីសិក្សាជាតិ។

**ប្រការ ៦.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវមានកិច្ចព្រមព្រៀងជាមួយគ្រឹះស្ថានបណ្តុះបណ្តាលក្នុងការទទួលយក និងបញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប ដើម្បីអនុវត្តកម្មសិក្សាគ្លីនិក។

**ប្រការ ៧.-**

គ្រឹះស្ថានបណ្តុះបណ្តាល ត្រូវធ្វើការសិក្សាឱ្យបានច្បាស់លាស់ ជាមួយគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ពីលទ្ធភាពបញ្ជូន និងបំពេញឱ្យបានគ្រប់តម្រូវការ នៃការអនុវត្តកម្មសិក្សាគ្លីនិករបស់និស្សិត។

### ផ្នែកទី ២
### ធនធានហិរញ្ញវត្ថុ

**ប្រការ ៨.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវមានកញ្ចប់ថវិកាគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការអនុវត្តកម្មសិក្សាគ្លីនិកប្រកបដោយគុណភាពរបស់និស្សិត។

ប្រភពថវិកានេះទទួលបានមកពី៖

- ថវិការដ្ឋ ចំពោះនិស្សិតដែលមកពីគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈដែលមិនមានចំណូល
- ថវិការបស់គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈដែលមានចំណូល និងឯកជន។

## ផ្នែកទី ៣
## រចនាសម្ព័ន្ធគ្រប់គ្រង និងអភិបាលកិច្ច

**ប្រការ ៩.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងការអនុវត្តកម្មសិក្សាគ្លីនិករបស់និស្សិត ក្រោមការទទួលខុសត្រូវរបស់ប្រធានផ្នែកថែទាំ ដោយមានការឯកភាពពីប្រធានគ្រឹះស្ថាន។

**ប្រការ ១០.-**

ប្រធានគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក និងប្រធានគ្រឹះស្ថានបណ្ដុះបណ្ដាលត្រូវអនុញ្ញាតឱ្យមានការសហការគ្នារវាងគ្រូកម្មសិក្សាមន្ទីរពេទ្យ និងគ្រូកម្មសិក្សាសាលា ក្នុងការជួយបង្រៀន តាមដាន និងវាយតម្លៃការអនុវត្តកម្មសិក្សារបស់និស្សិត។

**ប្រការ ១១.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវចាត់តាំងគ្រូកម្មសិក្សាមន្ទីរពេទ្យ និងអ្នកទទួលខុសត្រូវលើការបង្រៀន ការវាយតម្លៃ និងការផ្តល់សុពលភាពដល់ការអនុវត្តគ្លីនិករបស់និស្សិតឱ្យបានត្រឹមត្រូវតាមតួនាទី និងភារកិច្ចដែលបានកំណត់ក្នុងកម្មវិធីសិក្សាជាតិសម្រាប់គ្រូកម្មសិក្សាមន្ទីរពេទ្យ។

**ប្រការ ១២.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក និងគ្រឹះស្ថានបណ្ដុះបណ្ដាល ត្រូវទទួលខុសត្រូវ គ្រប់គ្រងវិន័យ និងរដ្ឋបាល លើការអនុវត្តកម្មសិក្សារបស់និស្សិត ដោយតម្រូវឱ្យនិស្សិតស្លៀកពាក់ឯកសណ្ឋានជានិស្សិតសមរម្យ។

ប្រធានគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក និងគ្រូកម្មសិក្សាមន្ទីរពេទ្យ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តកម្មសិក្សាគ្លីនិកអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ និងដែនកំណត់វិជ្ជាជីវៈ។

## ផ្នែកទី ៤
## ទីតាំង អគារ និងមូលដ្ឋានធនធានរូបវ័ន្ត

**ប្រការ ១៣.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវមានទីតាំង បន្ទប់សិក្សា បណ្ណាល័យ សមស្របសម្រាប់ជាជំនួយដល់ការសិក្សា និងស្រាវជ្រាវរបស់និស្សិតក្នុងការអនុវត្តកម្មសិក្សាគ្លីនិកដូចខាងក្រោម៖

- ផ្គត់ផ្គង់សម្ភារៈអនុវត្តគ្លីនិកសមស្របទៅតាមចំនួននិស្សិត និងជំនាញដែលត្រូវអនុវត្ត
- បណ្ណាល័យ៖ មានសៀវភៅ និងឯកសារផ្សេងៗ សម្រាប់និស្សិតសិក្សា និងស្រាវជ្រាវក្នុងការអនុវត្តកម្មសិក្សាគ្លីនិក និងបំពេញកិច្ចការ (Assignment) ដោយសហការជាមួយគ្រឹះស្ថានបណ្ដុះបណ្ដាល
- មានបន្ទប់ និងសម្ភារៈជំនួយបង្រៀនសមស្របសម្រាប់និស្សិតសិក្សា និងធ្វើបទបង្ហាញនានា
- មានបន្ទប់ផ្លាស់ប្ដូរសម្លៀកបំពាក់សម្រាប់និស្សិតសមរម្យ
- មានប្រព័ន្ធទឹកស្អាត និងភ្លើង សម្រាប់ជំនួយដល់និស្សិតក្នុងការចុះអនុវត្តកម្មសិក្សាគ្លីនិក។

## ផ្នែកទី ៥
## ការអនុវត្តកម្មសិក្សាគ្លីនិក

**ប្រការ ១៤.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវមានធនធានមនុស្ស ធនធានសម្ភារៈ និងករណីគ្លីនិក សមស្របតាមកម្មវិធីសិក្សាជាតិ ថ្នាក់បរិញ្ញាបត្ររងឆ្មប។

**ប្រការ ១៥.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវបំពេញលក្ខខណ្ឌបច្ចេកទេសតាមការតម្រូវដូចខាងក្រោម៖

- ផ្តល់នូវសេវាថែទាំ ដែលគោរពតាមការតម្រូវនៃស្តង់ដាកម្មវិធីសិក្សាជាតិ
- ត្រូវមានចំនួនករណីគ្លីនិក សម្រាប់និស្សិតម្នាក់ៗអនុវត្តឱ្យបានគ្រប់ចំនួនតាមការតម្រូវនៃករណីគ្លីនិកដូចមានចែងក្នុងកម្មវិធីសិក្សាជាតិ។ នៅពេលដែលចំនួនករណីគ្លីនិកមិនគ្រប់តាមការតម្រូវ គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកត្រូវជូនដំណឹងមកគ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីស្វែងរកករណីគ្លីនិកបន្ថែមនៅទីតាំងថ្មី សម្រាប់និស្សិតម្នាក់ៗ អនុវត្តឱ្យបានគ្រប់ចំនួន
- អនុបាតរវាងនិស្សិត និងអ្នកជំងឺ និង/ឬស្ត្រីមកទទួលសេវាតាមផ្នែកនីមួយៗនៃមន្ទីរពេទ្យ១:២
- អនុបាតរវាងគ្រូកម្មសិក្សាមន្ទីរពេទ្យ និងនិស្សិត មិនត្រូវលើសពី ១:៥។

**ប្រការ ១៦.-**

គ្រូកម្មសិក្សាមន្ទីរពេទ្យត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ជាឆ្មប ដែលមានគុណវុឌ្ឍិកម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាងកម្រិតកម្មវិធីសិក្សាដែលខ្លួនដឹកនាំកម្មសិក្សា
- មានបទពិសោធន៍ជំនាញយ៉ាងតិច ៣ឆ្នាំ នៅមូលដ្ឋានសុខាភិបាលសាធារណៈ ឬឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- បានទទួលការបណ្តុះបណ្តាលវគ្គគ្រូកម្មសិក្សាមន្ទីរពេទ្យ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- ត្រូវចុះបញ្ជិកា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុពលភាពពីគណៈឆ្មបកម្ពុជា។

**ប្រការ ១៧.-**

គ្រឹះស្ថានបណ្តុះបណ្តាល ត្រូវសហការជាមួយគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក រៀបចំការបណ្តុះបណ្តាលគ្រូកម្មសិក្សាមន្ទីរពេទ្យឱ្យបានសមស្របតាមតម្រូវការ ដោយប្រើប្រាស់កម្មវិធីសិក្សាជាតិសម្រាប់គ្រូកម្មសិក្សាមន្ទីរពេទ្យ និងទទួលស្គាល់ដោយក្រសួងសុខាភិបាល។

## ជំពូកទី ៣
## បែបបទក្នុងការទទួលស្គាល់ជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក

**ប្រការ ១៨.-**

មូលដ្ឋានសុខាភិបាល ដែលមានបំណងក្លាយជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវគោរពគ្រប់លក្ខខណ្ឌដូចមានចែងក្នុងជំពូកទី២ខាងលើ បំពេញបែបបទដាក់ពាក្យស្នើសុំ និងឆ្លងកាត់ការវាយតម្លៃពីក្រុមការងារជំនាញរបស់ក្រសួងសុខាភិបាល។

**ប្រការ ១៩.-**

សំណុំឯកសារដែលត្រូវបំពេញ និងដាក់ជូនក្រសួងសុខាភិបាលមានដូចខាងក្រោម៖

- លិខិតស្នើសុំការទទួលស្គាល់ដែលមានចុះហត្ថលេខាពីប្រធានអង្គភាព
- កិច្ចសន្យាអនុវត្តតាមស្តង់ដាអប្បបរមា នៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប
- ផែនការពីលទ្ធភាពទទួលយកនិស្សិតថ្នាក់បរិញ្ញាបត្ររងឆ្មប
- របាយការណ៍ពីស្ថានភាព និងចំនួននិស្សិតកំពុងអនុវត្តកម្មសិក្សាគ្លីនិកជាក់ស្តែង
- បញ្ជីឈ្មោះ និងចំនួនគ្រូកម្មសិក្សាមន្ទីរពេទ្យដែលទទួលបានការបណ្តុះបណ្តាល និងទទួលស្គាល់ដោយក្រសួងសុខាភិបាល
- ចំនួន និងទំហំបន្ទប់សម្រាប់និស្សិតអនុវត្តកម្មសិក្សា
- បញ្ជីឈ្មោះសម្ភារៈសម្រាប់និស្សិតអនុវត្តកម្មសិក្សា
- បញ្ជីឈ្មោះសៀវភៅ និងឯកសារផ្សេងៗសម្រាប់និស្សិតសិក្សា និងស្រាវជ្រាវ។

**ប្រការ ២០.-**

អាជ្ញាបណ្ណនៃការទទួលស្គាល់ ជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកមានសុពលភាពរយៈពេល ៥ (ប្រាំ)ឆ្នាំ ដែលចេញដោយក្រសួងសុខាភិបាល។

អាជ្ញាបណ្ណនេះនឹងត្រូវបញ្ចប់មុនផុតសុពលភាព ក្នុងករណីគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកអនុវត្តមិនត្រឹមត្រូវតាមស្តង់ដាអប្បបរមាដែលមានចែងក្នុងជំពូកទី២ នៃប្រកាសនេះ។

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក ត្រូវដាក់ពាក្យស្នើសុំមកក្រសួងសុខាភិបាល ដើម្បីទទួលយកការវាយតម្លៃសម្រាប់ការបន្តសុពលភាពឱ្យបាន ២ (ពីរ)ខែ មុនកាលបរិច្ឆេទផុតកំណត់។

## ជំពូកទី ៤
## ការពិនិត្យ តាមដាន និងវាយតម្លៃ

**ប្រការ ២១.-**

គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក និងគ្រឹះស្ថានបណ្តុះបណ្តាល ត្រូវបង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃការអនុវត្តកម្មសិក្សារបស់និស្សិតឱ្យបានជាប់ជាប្រចាំ។

**ប្រការ ២២.-**

អង្គភាពជំនាញនៃក្រសួងសុខាភិបាលត្រូវទទួលខុសត្រូវ តាមដាន និងវាយតម្លៃការអនុវត្តរបស់គ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក និងគ្រឹះស្ថានបណ្តុះបណ្តាល ព្រមទាំងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាលជាទៀងរាល់ឆ្នាំ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ ២៣.-**

មូលដ្ឋានសុខាភិបាលដែលកំពុងទទួលនិស្សិតថ្នាក់បរិញ្ញាបត្ររងធ្មប អនុវត្តកម្មសិក្សាគ្លីនិកមានរយៈពេល ២(ពីរ)ឆ្នាំ ដើម្បីបំពេញឱ្យគ្រប់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៥.-**

អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស គ្រប់ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងគ្រប់សាកលវិទ្យាធិការ នាយកគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**សាស្ត្រាចារ្យ ឈាង រ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- ក្រុមប្រឹក្សាសាកលវិទ្យាធិការកម្ពុជា
- សមាគមគ្រឹះស្ថានឧត្តមសិក្សា
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ ២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ